# ការធ្វើពិសោធន៍សមត្ថភាពគ្រាប់ពូជដោយប្រើ ការពិសោធន៍បណ្ដុះសាមញ្ញ

ECHO Asia Notes
A Regional Supplement to ECHO Development Notes

លេខ ១១ ខែតុលា ឆ្នាំ២០១១

ដោយបណ្ឌិត **Abram J. Bicksler**

អ្នកនិពន្ធ: **Abram** បំរើការជាអ្នកត្រួតពិនិត្យលើការស្រាវជ្រាវពីនិរន្តរភាព និងជាសាស្ត្រាចារ្យនៃវិទ្យាស្ថានសិក្សាពីការអភិវឌ្ឍន៏និរន្តរភាពអន្តរជាតិ ក្នុងខេត្តឈៀងម៉ៃ។ គាត់ក៏ជួយដល់ការិយាល័យអេកូតំបន់អាស៊ីជាទីប្រឹក្សាបច្ចេកទេសផងដែរ។

## សេចក្ដីសង្ខេប

ការរក្សាគ្រាប់ពូជដោយខ្លួនឯង គឺជាការមធ្យោបាយសន្សំសំចៃដ៏មានប្រសិទ្ធិភាពមួយ ក្នុងការប្រើប្រាស់គ្រាប់ពូជសំរាប់ដាំដុះទៅថ្ងៃអានាគត និងដើម្បីជួយថែរក្សាជីវចម្រុះរុក្ខជាតិរបស់ ផែនដីផង។ កាន់តែសំខាន់ជាងហ្នឹងទៀត ក្រៅពីដាំដោយប្រើគ្រាប់ពូជខ្លួនឯងហើយ អ្នកគួរឲ្យគ្រាប់ពូជ ទាំងនេះទៅឲ្យមិត្តនិងអ្នកជិតខាង ឬក៏ចែកចាយគ្រាប់ពូជទាំងនេះទៅដល់ស្ថាប័នរបស់អ្នក ដើម្បីឲ្យបានដឹងពីសមត្ថភាពរបស់គ្រាប់ពូជរបស់អ្នក។ សូមពិនិត្យបន្ថែមលើអត្ថបទចុះផ្សាយលេខ ៨ ខែមករា ឆ្នាំ២០១១ របស់ ECHO Asia Notes ចំណងជើង “ សង់បន្ទប់បណ្ដុះគ្រាប់ពូជដោយខ្លួនឯងសំរាប់ធ្វើការសាកល្បងពីសមត្ថភាពរបស់គ្រាប់ពូជ ” (www.echonet.org/repository#1003:d:Build%20Your%20Own%20Seed%20Germination%20Cabinet)
ចំណងជើងនេះនឹងបង្ហាញលំអិតពីវិធីធ្វើមួយចំនួនដោយចំណាយប្រាក់តិច ដើម្បីធ្វើការសាកល្បងពីសមត្ថភាពគ្រាប់ពូជ។

**សមត្ថភាពគ្រាប់ពូជ** គឺការវាស់ពីភាគរយនៃគ្រាប់ពូជដែលអាចរស់រាន បន្ទាប់ពីយកទៅស្តុកទុក។ គ្រាប់ពូជដែលល្អបំផុតរបស់អ្នក មានចំនួនតែ ២ ទៅ ៣ គ្រាប់ប៉ុណ្ណោះ ដែលអ្នកត្រូវការដើម្បីយកមកដាំនៅក្នុងចំការ ឬកន្លែងបណ្ដុះកូនឈើ។

ដើម្បីដឹងពីសមត្ថភាពរបស់គ្រាប់ពូជ គេអាចយកមកធ្វើការសាកល្បង ដោយប្រើវិធីងាយៗជាច្រើន។ ការសាកល្បងបណ្ដុះគ្រាប់ពូជ ស្ទើរតែជាវិធីមួយដ៏សាមញ្ញបំផុតទៅហើយ: គ្រាប់ពូជត្រូវបានដាក់ឲ្យត្រូវកន្លែងដែលមានប្រភព (ខ្យល់, ទឹក, កំដៅ និងពន្លឺ) ដើម្បីបណ្ដុះ និងលូតលាស់ ទៅ ជាកូនឈើបាន។ ជាធម្មតាគ្រាប់ពូជត្រូវបានគេដាក់ដាំនៅក្នុងដី ឬដាក់នៅក្នុងជើងផ្ដា ហើយតាមដានថាតើមានគ្រាប់ពូជ

ប៉ុន្មានដែលដុះលូតលាស់។ ទោះជាយ៉ាងណា គុណវិបត្តិ នៃការដាំនឹងដី, ជើង និងទីវាល គឺអាច ប្រែប្រួលតាមរយៈបរិស្ថានជុំវិញវា ដោយហេតុនេះធ្វើឲ្យយើងមានការពិបាកក្នុងការវិនិច្ឆ័យពីសមត្ថភាពពិតរបស់គ្រាប់ពូជ (ហេតុផលដែលបង្កឲ្យគ្រាប់ពូជមិនអាច លូតលាស់បានមាន ដូចជា គ្រាប់ខូច ឬហូរជន់តាមទឹក, រងការបំផ្លាញដោយផ្សិត, ទទួលកំដៅខ្លាំងពេក។ល។)។



រូបទី ១: ទូរបណ្ដុះគ្រាប់ (សូមមើលសេចក្ដីពិស្ដារស្ដីពីការសង់នៅក្នុងអត្ថបទ EAN ខែមករា ឆ្នាំ២០១១

ទូរបណ្ដុះគ្រាប់ពូជដែលណែនាំឲ្យប្រើ ដូចបានបង្ហាញនៅក្នុងអត្ថបទចុះផ្សាយមុន (រូបភាពទី ១) គឺជាវិធីមួយដ៏ល្អ សំរាប់ផ្ដល់នូវពន្លឺ និងសីតុណ្ហភាព ដើម្បីអាចឲ្យគ្រាប់លូតលាស់ ហើយរួមទាំងវិធីផ្សេងៗទៀតផងដែរ។ បើទោះជាទូរមិនពេញលក្ខណៈក៏អ្នកនៅតែអាចធ្វើការសាកល្បងពីសមត្ថភាពគ្រាប់ពូជដោយទុកចិត្តបានដែរ។

## របៀបធ្វើ

វិធីផ្សេងៗសំរាប់ពិនិត្យពីសមត្ថភាពគ្រាប់ពូជសុទ្ធតែប្រើសំរាប់ផ្ដល់ឲ្យគ្រាប់ពូជជាមួយសារធាតុ ដែលធ្វើសកម្មភាពនៅពេលមានអង់ស៊ីម ដែលជួយបង្កើតទឹកឡើងក្នុងបរិមាណសមរម្យសំរាប់គ្រាប់ពូជ អាចស្រូបយកសារធាតុចិញ្ចឹមបាន (ស្រូបចូលទៅក្នុងខ្លួនរបស់ពួកវាផ្ទាល់) ដើម្បីលូតលាស់។ វិធីធ្វើអាស្រ័យលើធនធានដែលអ្នកមាន ហើយត្រូវចាំថា ជាធម្មតាអ្នកអាចប្រើវិធីខុសៗគ្នាមួយចំនួន ដើម្បីធ្វើការប្រៀបធៀបពីលទ្ធផល ដែលទទួលបាន។

រាល់គ្រាប់ពូជត្រូវការលក្ខខណ្ឌពន្លឺ និងសីតុណ្ហភាពចាំបាច់ ប៉ុន្តែតាមច្បាប់ទូទៅដែលបានចែងថា គ្រាប់ពូជស្ទើរតែទាំងអស់នឹងដុះលូតលាស់ នៅពេលសីតុណ្ហភាពចន្លោះពី ២០ ទៅ ៣០ អង្សាសេ, សារធាតុទឹកគ្រប់គ្រាន់ក្នុងការធ្វើសកម្មភាពនៅពេលមានអង់ស៊ីម និងបរិមាណពន្លឺខ្លះ ដែលត្រូវផ្ដល់ទៅ គ្រាប់ពូជ (មើលតារាង ៥.១ នៅក្នុង " វិធីប្រើគ្រាប់ពូជនៅធនាគារគ្រាប់ពូជ " សំរាប់លក្ខខណ្ឌមួយចំនួន ដែលគ្រាប់ពូជត្រូវការ និងកាន់តែស៊ីជំរៅនៃការពិសោធន៍ពីសមត្ថភាពគ្រាប់)។

គ្រាប់ពូជសំរាប់ធ្វើពិសោធន៏គួរតែត្រូវជ្រើសរើសដោយច្រោះៗចេញពីគ្រាប់ពូជទាំងអស់របស់អ្នក។ តាមក្របខ័ណ្ឌអន្តរជាតិចំពោះគ្រាប់ពូជ ដែលយកមកធ្វើការពិសោធន៏ត្រូវការ ២០០ គ្រាប់ សំរាប់ការពិសោធន៏ពីការលូតលាស់។ ប្រសិនបើបរិមាណ ដែលបានកំណត់ខាងលើនេះពិបាកក្នុងការបង្គ្រប់វា ត្រឹមតែ ១០០ រឺយ៉ាងហោចណាស់ ៥០ គ្រាប់ ក៏អាចយកមកធ្វើការពិសោធន៏បានដែរ។ ចែកគ្រាប់ពូជទាំងអស់ជាពីរស្មើៗគ្នា ធ្វើដូចនេះអ្នកនឹងទទួលលទ្ធផល ២ ចំពោះការពិសោធន៏ពីការលូតលាស់។

*ប្រសិនបើអ្នកមានគ្រាប់ពូជ ច្រើនប្រភេទ (សាលាដ, ស្ពៃក្តោប, ប៉េងប៉ោះ ។ល។) ក្រោយពីការធ្វើពិសោធន៍ចំនួន ៤ ដង លើគ្រាប់ ពូជ ១០០ គ្រាប់ មក វានឹងផ្តល់នូវលទ្ធផលច្រើនបំផុត។*

**ការការពារមេរោគ**



រូបទី ២: ការត្រាំគ្រាប់សណ្តែកទ្រើងនៅក្នុងសូលុយស្យុងធ្វើឱ្យស ១ ភាគរយ (អាចប្រើប្រអប់ដាក់ធំជាងហ្នឹងផ្សេងទៀតក៏បាន ប្រសិនអ្នកមាន)។

*សកម្មភាពនៃការឆ្លងមេរោគតាមរយៈពពួកផ្សិត និងបាក់តេរី បើកើតឡើងនៅពេលធ្វើការពិសោធន៍ នោះវានឹងបណ្តាលឱ្យទទួលបាននូវលទ្ធផលមិនល្អ និងការសន្និដ្ឋាន ខុស។ បច្ចេកទេសសំលាប់មេរោគ ជាវិធីដ៏មានសារៈសំខាន់ដើម្បីកាត់បន្ថយនូវការឆ្លងមេរោគ ដោយសំលាប់ និងបន្ថយវត្តមានរបស់ មេរោគ។ ការសំអាត និងសំលាប់មេរោគនៅកន្លែងពិសោធន៍ ដោយ ប្រើសូលុយស្យុងអាកុល ៧០ ទៅ ៩៥ ភាគរយ ឬសូលុយស្យុងសំលាប់មេរោគ ២០ ភាគរយ (កុំភ្លេចលាងដៃរបស់អ្នក!)។ ប្រអប់ដាក់គ្រាប់បណ្តុះ និងដង្កៀបគួរយកទៅត្រាំនៅក្នុងទឹកសូលុយស្យុងសំលាប់មេរោគ ២០ ភាគរយ រយៈពេល ១០ ទៅ ១៥ នាទី ឬធ្វើការសំលាប់មេរោគជាមួយអាកុល។ បង្ការគ្រាប់ពូជពីការគរលើគ្នា និងដកចេញភ្លាមនូវគ្រាប់ ដែលខូច ឬរលួយ ធ្វើការកត់ត្រានូវគ្រាប់ពូជដែលឆ្លងមេរោគ។*



រូបទី៣ : ការកាត់ក្រដាសអនាម័យដាក់ចូលក្នុង កែវ **petri** : កាត់ក្រដាស អនាម័យដែលបត់ពីរដោយប្រើកន្ត្រៃបន្ទាប់មកតម្រឹមគែមបណ្តោយក្រដាសអនាម័យឱ្យត្រូវនឹងកែវ **petri** ។

*មធ្យោបាយងាយបំផុត ដើម្បីការពារការឆ្លងមេរោគ គឺយើងត្រូវសំអាតផ្ទៃខាងក្រៅរបស់គ្រាប់ មុនយកទៅពិសោធន៍។ ការលាយបញ្ចូលគ្នានៃសូលុយស្យុងធ្វើឱ្យសជាធម្មតាចន្លោះពី ៥ ទៅ ៦ ភាគរយ រៀបចំសូលុយស្យុង* sodium hypochlorite *ដោយបន្ថែម ៨០ មីលីលីត្រ នៃទឹកចំហាយ លាយជាមួយសារធាតុធ្វើឱ្យស។ ត្រាំគ្រាប់ពី ៣ ទៅ ៥ នាទី (៣ នាទី ចំពោះគ្រាប់តូច និងច្រើនជាង ៥ នាទី ចំពោះគ្រាប់ធំជាងគេដូចគ្រាប់សណ្តែក ដែលជាគ្រាប់ល្អ) នៅក្នុងសូលុយស្យុង ធ្វើឱ្យសល្មមសំរាប់បរិមាណសមរម្យ (រូបទី ២)។ ត្រូវជុសលាងគ្រាប់ឱ្យបានហ្មត់ចត់ ពី ៣ ទៅ ៥ ដង នៅក្នុងទឹកចំហាយ មុនយកវាទៅធ្វើការបណ្តុះ។*

## វិធីបណ្ដុះដោយគ្របក្រដាសពីលើ

*នៅក្នុងវិធីគ្របក្រដាសពីលើ គ្រាប់ត្រូវបានគេដាក់នៅលើក្រដាសបណ្ដុះនៅក្នុងប្រអប់ជាមួយគម្រប បិទជិត (ដើម្បីការពារការ បាត់បង់សំណើម)។ ស្នោ ឬកែវ petri ប្រើបានល្អសំរាប់វិធីនេះ។ ធនាគារគ្រាប់ពូជអាស៊ី អេកូ ប្រើប្រអប់ជ័រប្លនជ្រុងជាមួយគម្របបិទជិត។ ប្រើស្ទីតសំរាប់សរសេរលើប្រអប់ជ័រនូវប្រភេទរបស់គ្រាប់ ដែលត្រូវបានយកមកសាកល្បង និងចំនួនដង។ យកប្រអប់ ដែលគ្មាន មេរោគ ដែលបានរៀបរាប់ខាងលើ បន្ទប់មកកាត់ក្រដាសបណ្ដុះ (យើងប្រើក្រដាសអនាម័យពីរស្រទាប់) ដើម្បីដាក់ឲ្យត្រូវនឹងប្រអប់ជ័រ (រូបទី ៣)។*



រូបទី៤ : ប្រើដៃ ឬចន្ទេ សដែលសំលាប់មេរោគហើយ សង្កត់ក្រដាស់អនាម័យឱ្យចូលក្នុងកែវ **petri**។



រូបទី៥ : តុការងារល្អសំរាប់ធ្វើការពិសោធន៍ គួរមានកែវ **petri** ដាក់សណ្ដែកទ្រើង, សឺរាំងចាក់ទឹក, ទឹកសំលាប់មេរោគ និងគ្រាប់សំលាប់មេរោគហើយ។ ក្រោយធ្វើរួចគេនឹងយកវាទៅដាក់ក្នុងទូរបណ្ដុះ។

*ប្រើដៃ ឬដង្កៀប ដែលបានសំអាតមេរោគហើយ ដើម្បីញាត់ក្រដាសបណ្ដុះទៅក្នុងប្រអប់ជ័រ (រូបទី ៤)។ បន្ថែម បរិមាណចំហាយទឹកឲ្យត្រឹមត្រូវ (ប្រសិនមិនទឹកចំហាយទេ អាចប្រើទឹកពុះ ឬទឹកត្រជាក់ក៏បាន) ដើម្បីរក្សាក្រដាសឲ្យសើមជានិច្ច ប៉ុន្តែមិនត្រូវធ្វើឲ្យជោគទេ (រូបទី ៥)។ យើងបានរកឃើញថា ប្រភេទនៃប្រអប់ជ័រ ដែលមានដាក់ក្រដាសអនាម័យពីរត្រួត ត្រូវប្រើទឹក ២ ទៅ ៦ មីលីម៉ែត្រ អាស្រ័យលើទំហំរបស់ប្រអប់ជ័រ។*

*តម្រាបគ្រាប់ជាជួរនៅលើក្រដាសបណ្ដុះ ហើយមិនត្រូវឲ្យគ្រាប់ប៉ះគ្នាទេ (រូបទី ៦)។ បិទគម្រប ហើយដាក់ប្រអប់ជ័រទៅក្នុងស្បោងប្រកឲ្យជិត ដើម្បីជួយការពារកុំឲ្យសំណើមភាយចេញទៅក្រៅ (រូបទី ៧)។ អ្នកចង់ការពារការបាត់បង់សំណើម ប៉ុន្តែនៅតែត្រូវការអុកស៊ីសែនចេញចូល ដែលគ្រាប់នឹងត្រូវការដើម្បីលូតលាស់ និងស្រូបយក។*



រូបទី៦ ៈ គ្រាប់សណ្តែកទ្រើងដាក់ពង្រាយលើក្រដាសអនាម័យសើម ដោយប្រើចង្កឹះ (មិនបាច់រៀបពួកវាឱ្យត្រង់ជួរទេ ពេកទេ ប៉ុន្តែមិនអាចប៉ះគ្នាបានទេ បើមិនដូច្នោះទេវានឹងឆ្លងមេរោគ)។ ខ្ញុំប្រើគ្រាប់ ចំនួន ២៥ ដាក់ក្នុងកែវ **petri** ក្នុងការពិសោធន៍ម្តងៗ ពីព្រោះការដាក់ជា ជួរជួយឱ្យខ្ញុំអាចដាក់បាន ២៥ គ្រាប់ក្នុងកែវ **petri** និមួយៗ។



រូបទី៧ ៈ បិទកែវ **petri** ដោយច្រកស្បោងឱ្យរលុង ដែលមានសរសេរឈ្មោះពីលើ ហើយច្រកគែមខាងក្រោមឱ្យរលុង (ដើម្បីទប់សំណើម ប៉ុន្តែមិនឱ្យខ្យល់ចូលជាដាច់ខាត)។

*ដាក់ប្រអប់ជ័រនៅក្នុងទូបណ្តុះគ្រាប់របស់អ្នក ឬក៏នៅកន្លែងមានពន្លឺខ្លះ ហើយមានសីតុណ្ហភាពក្តៅល្មម។ រៀងរាល់ថ្ងៃ ឬមួយថ្ងៃខានមួយថ្ងៃ ត្រូវរាប់, កត់ត្រា និងដកចេញនូវគ្រាប់ដែលបានបណ្តុះ។ ការបណ្តុះគឺគេចង់កំណត់នូវការដុះពន្លកដោយមិនមានការរាំងស្ទះ ឬពន្លកឫសល្អ ឬឫសគ្រាប់ចេញពីស្រទាប់របស់គ្រាប់ (រូបទី ៨, ៩)*



រូបទី៨ ៈ គ្រាប់ **amaranth** ក្រោយ ១ ថ្ងៃ គេអាចរាប់ជាគ្រាប់ដុះពន្លក និងបោះចោល។



រូបទី៩: ការដុះឫសពន្លករបស់គ្រាប់សណ្តែកទ្រើងបន្ទាប់ពី ១ ថ្ងៃ។ គ្រាប់ទាំងនេះត្រូវបានគេគិតថា ជាគ្រាប់ដុះ និងគ្រាប់ ដែលត្រូវដកចោល។

សារធាតុដែលមានសកម្មភាពនៅពេលមានអង់ស៊ីម នឹងស្ទើរតែត្រូវការសំណើម នៅពេលធ្វើការសាកល្បង ដោយធ្វើយ៉ាងណាឲ្យកន្លែងដាក់គ្រាប់មានប្រភេទគ្រាប់ដូចគ្នាទទួលបានបរិមាណទឹកស្មើគ្នា ដើម្បីសង្កេតពីបរិមាណ។ ការបណ្តុះគ្រាប់ស្ទើរទាំងអស់ គួរប្រើពេលបណ្តុះដល់ទៅ ១៤ ថ្ងៃ ប៉ុន្តែប្រភេទស្មៅខ្លះត្រូវការពេលដល់ទៅ ២៨ ថ្ងៃ ដើម្បីបណ្តុះ។ ប្រសិនបើ អ្នកចង់បណ្តុះគ្រាប់ទាំងអស់អ្នកប្រហែលជាត្រូវសំរេចចិត្តថា តើគួរធ្វើការពិសោធន៍ ដោយប្រើរយៈពេលខ្លីជាង ឬវែង ដោយផ្អែកលើប្រភេទ

*របស់គ្រាប់នោះ។ នៅពេលសាកល្បង ប្រុងប្រយ័ត្នក្នុងការដក និងបោះចោលនូវគ្រាប់ណា ដែលលិច ចេញនូវការឆ្លងមេរោគ ឬរលួយ។*

## វិធីបណ្ដុះចន្លោះក្រដាស

*ក្រដាសអនាម័យធម្មតា ត្រូវបានគេប្រើជាក្រដាសបណ្ដុះ និងក៏ធ្វើជាប្រអប់ផ្ទុកនូវ គ្រាប់ដែរ នៅក្នុងវិធីបណ្ដុះចន្លោះក្រដាស ។ កាត់ក្រដាសអនាម័យទំហំល្មម ដើម្បីអាចដាក់គ្រាប់ទាំងអស់បាន ដោយតម្រាបជាជួរឲ្យស្អាតនៅលើក្រដាស។ ប្រើខ្មៅដៃ ឬស្វីត សំរាប់សរសេរលើគែមក្រដាសអនាម័យ នូវប្រភេទគ្រាប់ដែលបានធ្វើការសាកល្បង និងចំនួនដងនៃការសាកល្បង។ ជ្រលម (ប៉ុន្តែកុំត្រាំ) ក្រដាសអនាម័យជាមួយទឹកចំហាយ។*

*បន្ទាប់មក តម្រាបគ្រាប់ជាជួរលើក្រដាសសើម ដោយដាក់ឲ្យឃ្លាតពីគែមក្រដាស ៣ សង្ទីម៉ែត្រ ហើយធ្វើយ៉ាងណាកុំឲ្យគ្រាប់ប៉ះគ្នា។ កន្លែងទំនេរនៅខាងក្រោមរបស់ក្រដាសត្រូវបានគេទុកសំរាប់ត្រាំទឹក។ គ្របគ្រាប់ជាមួយក្រដាសសើមផ្សេងទៀត រួចហើយមូលក្រដាសពីគែមដែលមិនបានសរសេរ (រូបទី ១០)។ ប្រើដង្កៀប ឬកៅស៊ូកងភ្ជាប់ដុំក្រដាស ដែលបានមូលហើយ ។ គ្រាប់នឹងនៅខាងក្នុងដុំក្រដាស ដែលបានរឹតនៅចន្លោះស្រទាប់ក្រដាសសើមពីរ។*



រូបទី១០: ការតម្រាបគ្រាប់នៅក្នុង "វិធីបណ្ដុះតាមចន្លោះក្រដាស។" ដោយ **Rao** ២០០៦

*ដាក់ផ្នែកខាងក្រោមដុំក្រដាសទៅក្នុងប្រអប់ជ័រ ដែលមានបាតជ្រៅ ដោយដាក់ទឹកឲ្យគ្រប់គ្រាន់ ដើម្បីធ្វើយ៉ាងណាឲ្យដុំក្រដាសអាចជ្រាបទឹកបាន (រូបទី ១១)។ បន្ទាប់មកដាក់ដុំក្រដាសទាំងនោះនៅក្នុងទូរបណ្ដុះ ឬកន្លែងមានសីតុណ្ហភាព និងពន្លឺក្ដៅលម្ម ។ រាប់, កត់ត្រា និងដកចេញគ្រាប់ដែលបានបណ្ដុះ ដោយពន្លាដុំក្រដាស ហើយមូលវាវិញបន្ទាប់ពីកត់ត្រាហើយ។*



រូបទី១១: ការមូល និងត្រួតពិនិត្យនៅក្នុង "វិធីបណ្ដុះតាមចន្លោះក្រដាស។" ដោយ **Rao** ២០០៦

ត្រូវកំរិតទឹកនៅក្នុងប្រអប់ជ័រឲ្យបានត្រឹមត្រូវ អ្នកប្រហែលជាអាចប្រើប្រដាប់បាញ់ទឹកទៅផ្នែកខាងលើរបស់ដុំក្រដាស ដើម្បីរក្សាភាពសើមជានិច្ច។ ស្រដៀងគ្នាចំពោះផ្នែកខាងលើរបស់ដុំក្រដាស គួរតែត្រួតពិនិត្យ និងបន្តការពិសោធន៏ដល់ ១៤ ថ្ងៃ ( ប្រសិនបើ អ្នកចង់បណ្ដុះគ្រាប់ទាំងអស់ អ្នកប្រហែលជាត្រូវសំរេចចិត្តថា តើគួរធ្វើការពិសោធន៏ ដោយប្រើរយៈពេលខ្លីជាង ឬវែង ដោយផ្អែកលើប្រភេទរបស់គ្រាប់នោះ )។ យកចិត្តទុកដាក់ជាពិសេស ក្នុងការដកចេញ និងបោះចោលនូវគ្រាប់ណា ដែលឃើញថាមានមេរោគឆ្លង ឬរលួយ។

## វិធីបណ្ដុះដោយប្រើខ្សាច់

ខ្សាច់សើម ឬវត្ថុដែលងាយជ្រាបទឹក គឺត្រូវបានគេប្រើជាឧបករណ៍បណ្ដុះគ្រាប់ នៅក្នុងវិធីបណ្ដុះដោយប្រើខ្សាច់។ ការចាប់ផ្ដើមជាមួយខ្សាច់ល្អ និងសំអាត ដែលអ្នកបានទិញ ឬប្រើកំដៅសំលាប់មេរោគ លើខ្សាច់ (ប្រសិនបើជាធ្វើបាន) ហើយចាក់ចូលទៅក្នុងបាតប្រអប់ជ័រខាងក្រោម ដោយមានរន្ធបង្ហូរទឹកត្រឹមត្រូវ។ ចាក់ទឹកលើដីខ្សាច់ ជាមួយទឹកដែលបានមកពីចំហាយរហូតដល់សើម ប៉ុន្តែមិនត្រូវត្រាំទឹកទេ (អ្នកមិនចង់ឲ្យខ្សាច់ហូរចេញពីប្រអប់ជ័រតាមរន្ធបង្ហូរទឹកទេ)។

បង្កើតរន្ធចំងាយស្មើៗគ្នានៅលើដីខ្សាច់ (ខ្មៅដៃ ឬស្វឹតអាចយកប្រើបានសំរាប់ចុះរន្ធទាំងនេះ) ជំរៅដូចទៅនឹងប្រវែងរបស់គ្រាប់ ដែលអ្នកយកមកពិសោធន៏ និងគម្លាត ៣ ដង នៃប្រវែងរបស់គ្រាប់។ ប្រសិនបើអ្នកកំពុងពិសោធន៏ច្រើនជាងមួយប្រភេទ គួរប្រើបង្គោរឈើតូច ឬជ័រប្លាស្ទិក ដើម្បីធ្វើជារង ដោយដាក់ឈ្មោះគ្រាប់ ដែលយកមកពិសោធន៏ និងចំនួនដងនៃការសាកល្បង។ ដាក់មួយគ្រាប់ក្នុង ១ រន្ធ គ្របដីខ្សាច់ពីលើ ហើយស្រោចទឹកលើប្រអប់ជ័រទាំងមូល។ ត្រូវប្រយ័ត្នពេលស្រោចទឹកលើប្រអប់ជ័រ មិនត្រូវឲ្យគ្រាប់ខ្ទាតចេញទេ (រូបទី ១២)។ យកប្រអប់ជ័រ ដែលបានរៀបចំហើយដាក់ក្នុងទូបណ្ដុះគ្រាប់ ឬនៅកន្លែងដែលមានពន្លឺ និងក្ដៅល្មម។



រូបទី១២: ការដាំគ្រាប់នៅក្នុង "វិធីបណ្តុះដោយប្រើដីខ្សាច់" ដោយ **Rao** ២០០៦

រាប់ និងកត់ត្រាគ្រាប់ដែលបានបណ្តុះរាងរាល់ថ្ងៃ ឬមួយថ្ងៃខានមួយថ្ងៃ។ ទោះជាយ៉ាងណា វាមិនចាំបាច់ដើម្បីដកចេញគ្រាប់ដែលបានបណ្តុះ លុះត្រាតែវាគរពីលើគ្នា។ បើអ្នកជ្រើសដកចេញនូវកូនបណ្តុះដោយដកទៅដាក់កូនបណ្តុះតាមកន្លែងដើម នោះវានឹងធ្វើឲ្យកូនកូនបណ្តុះងាប់ ហើយធ្វើឲ្យរបូតចេញនូវគ្រាប់ដែលមិនទាន់ដុះពីដីខ្សាច់ទៀត។

រក្សាសំណើមដីខ្សាច់នៅក្នុងពេលពិសោធន៍ ប៉ុន្តែមិនត្រូវស្រោចទឹកបន្ថែមទេ (រូបទី ១៣)។ ដូចគ្នាក្នុងវិធីពីរផ្សេងទៀត ការថែទាំ និងបន្តការបិសោធន៍រហូតដល់ ១៤ ថ្ងៃ អាស្រ័យលើប្រភេទគ្រាប់ ហើយប្រសិនបើ អ្នកចង់បណ្តុះគ្រាប់ទាំងអស់។



រូបទី១៣: ការស្រោចទឹក និងត្រួតពិនិត្យគ្រាប់នៅក្នុង"វិធីបណ្តុះដោយប្រើ ដីខ្សាច់" ដោយ **Rao** ២០០៦

| ការពិសោធន៏ពីភាពអាចរស់បានរបស់គ្រាប់<br>ការប្រមូលទិន្នន័យនៃការបណ្តុះគ្រាប់ និងការគណនា | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ចំនួនថ្ងៃបន្ទាប់ពីចាប់ផ្តើមធ្វើការសាកល្បង | | | | | | | | | |
| ចំនួនដង | ប្រភេទគ្រាប់ | ថ្ងៃខែចាប់ផ្តើម | ចំនួនគ្រាប់ | ២ | ៤ | ៦ | ៨ | ១០ | ១២ | ១៤ | ការបណ្តុះសរុប | ភាគរយនៃការបណ្តុះ | ថ្ងៃមធ្យមធៀបនឹងការបណ្តុះ ៥០% |
| ១ | សណ្តែក | ២០-មិថុនា | ១០០ | ៣៣ | ២០ | ១៨ | ១០ | ៧ | ៣ | ០ | ៩១ | ៩១ | ៤,៨៤ |
| ២ | | | | | | | | | | | | | |
| ៣ | | | | | | | | | | | | | |
| ៤ | | | | | | | | | | | | | |
| ១ | | | | | | | | | | | | | |
| ២ | | | | | | | | | | | | | |
| ៣ | | | | | | | | | | | | | |
| ៤ | | | | | | | | | | | | | |

រូបទី១៨: តារាងទិន្នន័យនៃការបណ្តុះសាមញ្ញជាមួយទិន្នន័យឧទាហរណ៍ពណ៌ក្រហម។
**Click here for the Excel data sheet.**

## ការវិភាគពីលទ្ធផល

ប្រើតារាងប្រមូលទិន្នន័យធម្មតា (រូបទី ១៨) ដើម្បីរាប់ និងកត់ត្រាគ្រាប់ដែលបានបណ្តុះលើការធ្វើការសាកល្បងរបស់អ្នក។ ការកត់ត្រាចំនួនសរុបនៃគ្រាប់ ដែលអ្នកចាប់ផ្តើមជាមួយការសាកល្បងម្តងៗ។ ក៏កត់ត្រាពីចំនួននៃគ្រាប់ដែលបានបណ្តុះ និងចំនួនគ្រាប់ដែលបានដកចេញពីការសាកល្បង នៅពេលគ្រាប់ឆ្លងមេរោគ ឬរលួយ (ទាំងនេះចុងក្រោយយើងនឹងមិនរាប់ថា អាចរស់បាន)។

ភាគរយសរុបនៃការបណ្តុះ គឺគណនាពីភាពអាចរស់បានទាំងអស់នៃគ្រាប់ដែលមាន ពីព្រោះអាចប៉ាន់ប្រមាណពីចំនួនគ្រាប់ ដែលនឹងដុះលូតលាស់ទៅជារុក្ខជាតិ នៅពេលអ្នកដាំពួកវា។ នៅចុងបញ្ចប់នៃការពិសោធន៏ ត្រូវបន្ថែមចំនួនរបស់គ្រាប់ ដែលត្រូវបណ្តុះក្នុងថ្ងៃនិមួយៗនៃការសាកល្បង ដោយចែកការបូកសរុបនោះ ជាមួយចំនួនសរុបរបស់គ្រាប់ ដែលចាប់ផ្តើមធ្វើការសាកល្បង ហើយគុណនឹង ១០០ ដើម្បីគណនាពីតួលេខនៃភាគរយនៃការបណ្តុះសរុប។ រើសយកការបណ្តុះសរុបគិតជាភាគរយសំរាប់ការពិសោធន៏រាល់លើក ដូច្នេះអ្នកអាចដឹងថាតើប៉ុន្មានលើកមានភាពខុសគ្នាឬអត់។ ប្រសិនខុសគ្នាច្រើន យកល្អធ្វើការសាកល្បងម្តងទៀត ជាមួយចំនួនច្រើនជាងហ្នឹងនៃគ្រាប់ ហើយច្រើនដង។

ទិន្នន័យ ដែលអ្នកប្រមូលបានអាចត្រូវបានគេប្រើដើម្បីវាយតំលៃពីរយៈពេល ដែលយើងទទួលបានចំនួន ៥០ ភាគរយ នៃគ្រាប់ ដែលដុះពន្លក។ អ្នកអាចគណនា " ជាមធ្យមនៃថ្ងៃ ក្នុងការបណ្តុះបាន ៥០ ភាគរយ" ដូចជា: សំរាប់ថ្ងៃនិមួយៗ គុណចំនួនរបស់គ្រាប់ ដែលបានបណ្តុះ ជាមួយថ្ងៃដែលអ្នកបានរាប់ពួកវា ក្រោយមកបូកតំលៃទាំងអស់ ហើយចែកចំនួននោះនឹងចំនួន សរុបរបស់គ្រាប់ដែលបានបណ្តុះ។ ឧទាហរណ៍: ប្រសិនបើ គ្រាប់ដែលបានបណ្តុះមានចំនួន ១២ គ្រាប់ នៅថ្ងៃទី១, ៨ គ្រាប់

នៅថ្ងៃទី៣ និង ៤ គ្រាប់នៅថ្ងៃទី៥ ដូច្នេះការបណ្ដុះគ្រាប់សរុប ២៤ ចំនួនថ្ងៃជាមធ្យម ចំពោះ ៥០ ភាគរយ នៃការបណ្ដុះ នឹងត្រូវគណនាជា ( ១ x ១២ + ៣ x ៨ + ៥ x ៤ )/២៤= ២,៣ ថ្ងៃ។

## សេចក្ដីបញ្ចប់

ការពិសោធន៍សមត្ថភាពរបស់គ្រាប់ពូជអ្នក ដោយធ្វើការសាកល្បងបណ្ដុះគ្រាប់ គឺជាមធ្យោបាយសំខាន់មួយ ដើម្បីស្រាវជ្រាវរកនូវគុណភាពរបស់គ្រាប់ពូជរបស់អ្នក, ដើម្បីពិនិត្យពីប្រសិទ្ធភាពនៃរបៀបស្តុកទុកគ្រាប់ពូជរបស់អ្នក និងដើម្បីជួយអ្នកប្រើប្រាស់គ្រាប់ពូជក្នុងបរិមាណសមរម្យសំរាប់ដាំដុះ។ ដោយធ្វើការសាកល្បងពីសមត្ថភាពរបស់គ្រាប់ពូជតាមវិធីសាមញ្ញទាំងនេះ អ្នកអាចបង្កើននូវ ប្រសិទ្ធភាពនៃការសន្សំសំចៃ និងជួយជំរុញឲ្យកសិករក្នុងសន្សំ និងដាំប្រភេទពូជសំខាន់ៗដទៃទៀត។

## ប្រភពឯកសារបន្ថែម


Gosling, P.G. “Viability testing.” Chapter 24: Seed Conservation. London: Kew Royal Botanical Gardens. *Available:* www.kew.org/science-research-data/kew-in-depth/msbp/publications-data-resources/technical-resources/seed-conservation-science-practice/SCTSIP_chapter24.htm.

Rao, N. K., J. Hanson, M. E. Dulloo, K. Ghosh, D. Nowell, and M. Larinde. 2006. Handooks for Genebanks No. 8: Manual of Seed Handling in Genebanks. Rome: Biodiversity International. *Available:* http://www.bioversityinternational.org/index.php?id=19&user_bioversitypublications_pi1[showUid]=3020.

Douglas, J. L., J. M. Grabowski, and L. E. Daughtry. 2003. "How to use a ragdoll test to estimate field germination." Plant Solutions for Conservation Needs. Plant Note #5. *Available*: ftp://ftp-fc.sc.egov.usda.gov/GA/PMC/JLW/ragdoll.pdf.